ជំនួយមូលនិធិប្រព័ន្ធផ្សព្វផ្សាយកម្ពុជា
Cambodia
Media Grant

## What are the Sustainable Development Goals?
## តើអ្វីទៅជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព?

In 2015, all countries in the UN came together to agree on the Sustainable Development Goals (SDGs). It was a pledge to protect the planet, and to make sure every human being could live in peace and prosperity, with the aim of making all this happen by 2030.

Even though there are 17 goals, they are all linked and the key focus is to prioritise helping those who were furthest behind. Achieving these goals requires everyone to be involved.

The five goals below are the focus of the Cambodia Media Grant project.

នៅក្នុងឆ្នាំ ២០១៥ បណ្តាប្រទេសក្នុងអង្គការសហប្រជាជាតិទាំងអស់បានធ្វើកិច្ចព្រមព្រៀងលើ គោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការអនុវត្តគោលដៅនេះគឺជាការសន្យាដើម្បីការពារភពផែនដី និងដើម្បីធានាថា មនុស្សគ្រប់រូបអាចរស់នៅដោយសុខសន្តិភាព និងវិបុលភាពដោយគោលដៅនេះមានគោលបំណង ធ្វើអោយកើតឡើងនៅឆ្នាំ ២០៣០។

ទោះបីជាមានគោលដៅចំនួន ១៧ ក៏ដោយក៏គោលដៅទាំងនោះសុទ្ធតែមានទំនាក់ទំនងគ្នាហើយការផ្តោតសំខាន់គឺផ្តល់អាទិភាពដល់ការជួយដល់អ្នកដែលមានស្ថានភាពក្រោយគេបំផុត។ ដើម្បីសំរេចគោលដៅទាំងនេះ តម្រូវឱ្យមនុស្សគ្រប់គ្នាមានការចូលរួម។

គោលដៅចំនួន ៥ខាងក្រោមនេះគឺជាគោលដៅដែលផ្តោតនៅក្នុងគម្រោង ជំនួយ មូលនិធិប្រព័ន្ធផ្សព្វផ្សាយកម្ពុជា។

---

### GOAL 2: ZERO HUNGER

*Food should be safe, sufficient and affordable for all!*

### គោលដៅទី ២៖ គ្រោះអត់ឃ្លានស្មើសូន្យ

ស្បៀងត្រូវតែមានសុវត្ថិភាព អាចផ្គត់ផ្គង់គ្រប់គ្រាន់ និងមានតំលៃសមរម្យសម្រាប់ទាំងអស់គ្នា!

Even before Covid-19, the number of people was impacted by hunger was on the rise. In 2019, more than 690 million people were undernourished, and if trends continue, more than 840 million people will go hungry by 2030. We all want our families to have enough safe and nutritious food to eat. A world with zero hunger can positively impact our economies, health, education, equality and social development.

The pandemic has added to the existing issues facing food systems, and small-scale food producers have been greatly hurt by the crisis. Investment in the agricultural sector is critical for reducing hunger and poverty, improving food security, creating employment and building resilience to disasters and shocks.

សូម្បីតែស្ថានភាពមុនពេល Covid-19 ចំនួនប្រជាជនដែលរងផលប៉ះពាល់ដោយភាព អត់ឃ្លានកំពុងកើនឡើង។ នៅឆ្នាំ ២០១៩ ប្រជាជនជាង ៦៩០ លាននាក់ ជួបប្រទះនូវរបបខ្វះ អាហារូបត្ថម្ភ ហើយប្រសិនបើបញ្ហានេះនៅតែបន្ត ប្រជាជនជាង ៨៤០ លាននាក់នឹងជួបប្រទះ នូវភាពអត់ឃ្លាន នៅឆ្នាំ ២០៣០។ យើងទាំងអស់គ្នាចង់អោយគ្រួសាររបស់យើងមានសុវត្ថិភាពស្បៀង និងជីវជាតិគ្រប់គ្រាន់សម្រាប់បរិភោគ។ ពិភពលោកដែលមានភាពអត់ឃ្លានស្មើសូន្យ អាចជះឥទ្ធិពលជាវិជ្ជមានដល់សេដ្ឋកិច្ច សុខភាព ការអប់រំ សមភាព និងការអភិវឌ្ឍសង្គម។

ការរីករាលដាលនៃមេរោគ បានបន្ថែមទៅលើបញ្ហាដែលមានស្រាប់ ដែលប្រឈមនិង ប្រព័ន្ធស្បៀងអាហារ ហើយ អ្នកផលិតចំណីអាហារខ្នាតតូចបានរងផលប៉ះពាល់យ៉ាងខ្លាំង ដោយសារវិបត្តិនេះ។ ការវិនិយោគលើវិស័យកសិកម្ម មានសារៈសំខាន់ណាស់សម្រាប់ការកាត់ បន្ថយភាពអត់ឃ្លាន និងភាពក្រីក្រធ្វើអោយប្រសើរឡើងនូវសន្តិសុខស្បៀង បង្កើតការងារ និងកសាងភាពរឹងមាំ នឹងគ្រោះមហន្តរាយ និងវិបត្តិនានា។

## Goal 3: GOOD HEALTHY AND WELL-BEING

*Ensure healthy lives, promote well-being of everyone*

## គោលដៅទី ៣៖ សុខភាព និង សុខុមាភាពមាំមួន

ធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប

Ensuring healthy lives and promoting well-being is important to building prosperous societies. However, the COVID-19 pandemic has devastated health systems globally and threatens the progress that has already been made. The pandemic has shown that all over the world, a health emergency can push people into bankruptcy or poverty.

More efforts are needed to fully eradicate a wide range of diseases and address many different persistent and emerging health issues. By focusing on providing more efficient funding of health systems, improved sanitation and hygiene, and increased access to physicians, significant progress can be made in helping to save the lives of millions.

ការធានាឱ្យមានជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អនិងលើកកម្ពស់សុខុមាលភាព គឺមានសារៈសំខាន់ ក្នុងការកសាងសង្គមរុងរឿង។ ទោះយ៉ាងណាក៏ដោយការរីករាលដាល នៃមេរោគ (COVID-១៩) បានបំផ្លិចបំផ្លាញ ប្រព័ន្ធសុខាភិបាលទូទាំងពិភពលោក និងគំរាម កំហែងដល់ការវិវត្តដែលមានស្រាប់ហើយ។ ការរីករាលដាលនៃមេរោគនេះ បានបង្ហាញអោយទូទាំងពិភពលោកឃើញថា ភាពអាសន្នផ្នែកសុខាភិបាល អាចជំរុញឱ្យមនុស្សខាតបាត់បង់ ឬទៅរកភាពក្រីក្រ។

យើងត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីលុបបំបាត់ជំងឺរាតត្បាតទាំងនេះ និងដោះស្រាយបញ្ហាសុខភាព ដែលចេះតែកើតមានឡើង។ តាមរយៈការផ្តោតលើការផ្តល់ថវិកា ប្រកបដោយប្រសិទ្ធភាពប្រសើរជាងមុនសម្រាប់ប្រព័ន្ធសុខាភិបាល ការលើកកម្ពស់អនាម័យ និងការបង្កើនគ្រូពេទ្យបង្គោលអោយបានកាន់មានប្រសិទ្ធិភាពអាចជួយក្នុងការជួយសង្គ្រោះជីវិតមនុស្សរាប់លាននាក់។

## Goal 12: RESPONSIBLE CONSUMPTION AND PRODUCTION

*Reduce your waste, support sustainable options, get plastic free, recycle!*

## គោលដៅទី ១២៖ ការប្រើប្រាស់និងការផលិតប្រកបដោយការទទួលខុសត្រូវ

កាត់បន្ថយសម្រាមរបស់អ្នក គាំទ្រជម្រើសដែលមានចីរភាព មិនមានផ្លាស្ទិក ការប្រើឡើងវិញ

The world continues to use natural resources unsustainably and in a way that continues to have destructive impacts on our planet. The progress that we have made as a global community has also been accompanied by the destruction of the very systems on which our future survival depends.

The Covid-19 does offer an opportunity for countries to develop recovery plans that can help reverse current trends and shift us onto a more sustainable course towards the future. Sustainable consumption and production simply means doing more while using less, finding ways to be more efficient with the resources we have, and promoting a sustainable lifestyle.

ពិភពលោកនៅតែបន្តប្រើប្រាស់ធនធានធម្មជាតិដោយគ្មាននិរន្តរភាព និងនៅតែតាម របៀបមួយដែលបន្តបំផ្លិចបំផ្លាញដែលជះឥទ្ធិពលនៅលើផែនដីយើង ។ ដំណើរការនៃការវិវត្ត ដែលយើងធ្វើក្នុងរូបភាពជាសកល បានបំផ្លាញជាប្រព័ន្ធទៅលើអនាគតដែលយើងត្រូវការ ពឹងផ្អែកក្នុងការរស់រាន ។

Covid-19 ពិតជាផ្តល់នូវឱកាសមួយសម្រាប់ប្រទេសនានាដើម្បីរៀបចំផែនការស្តារឡើងវិញ ដែលអាចជួយបញ្ជៀសនូវស្ថានភាពបច្ចុប្បន្ន និងបង្វែរយើងឆ្ពោះទៅរកអនាគតប្រកប ដោយ ចីរភាព ។ ការប្រើប្រាស់ និងផលិតប្រកបដោយនិរន្តរភាព មានន័យថា ធ្វើបានកាន់តែច្រើន ក្នុងពេលការប្រើប្រាស់តិច រកវិធីប្រើប្រាស់ធនធានអោយមានប្រសិទ្ធិភាព និងលើកកម្ពស់របៀប រស់នៅប្រកបដោយចីរភាព ។

## Goal 13: CLIMATE ACTION

*Combat global warming!*

## គោលដៅទី ១៣៖ សកម្មភាពបរិស្ថាន

ប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ

2020 and 2019 were two of the three warmest years on record, and also the end of the warmest decade (2010- 2019) ever recorded. Climate change is affecting every country on every continent, and Cambodia is considered one of the most vulnerable countries to climate change impacts such as floods and droughts.

Although greenhouse gas emissions are expected to drop slightly in 2020, this is only temporary. Once the global economy begins to recover, emissions are expected to return to higher levels. Already, we have seen how climate change has exacerbated the frequency and severity of natural disasters.

To address climate change, urgent action is needed to transition to renewable energy, reduce carbon emissions, and invest in sustainable solutions.

ឆ្នាំ ២០២០ និង ២០១៩ គឺជាឆ្នាំដែលក្តៅបំផុត ក្នុងចំណោមឆ្នាំទាំង៣ ក្នុងកំណត់ត្រា ហើយបញ្ចប់ឆ្នាំដែលក្តៅបំផុតនៃទសវត្ស (ឆ្នាំ ២០១០-២០១៩) ។ បម្រែបម្រួលអាកាសធាតុកំពុងជះឥទ្ធិពលគ្រប់ ប្រទេសគ្រប់ ទ្វីបទាំងអស់ហើយ ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសមួយដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតជាដើម។

ទោះបីជាការបំភាយឧស្ម័នផ្ទះកញ្ចក់ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះបន្តិចនៅឆ្នាំ ២០២០ ក៏ដោយ ក៏នេះគ្រាន់តែជាការបណ្តោះអាសន្នប៉ុណ្ណោះ។ នៅពេលដែលសេដ្ឋកិច្ចពិភពលោកចាប់ផ្តើម ងើបឡើងវិញ គេរំពឹងទុកថាការសាយភាយនឹងវិលត្រឡប់ទៅរកកម្រិតខ្ពស់វិញ។ យើងបាន ឃើញរួចមកហើយថា ការផ្លាស់ប្តូរអាកាសធាតុបានធ្វើអោយគ្រោះមហន្តរាយ កើតឡើងកាន់ តែញឹកញាប់ និងធ្ងន់ធ្ងរឡើងថែមទៀត។

ដើម្បីដោះស្រាយបំរែបំរួលអាកាសធាតុនេះ ចាំបាច់ត្រូវធ្វើសកម្មភាពផ្លាស់ប្តូរជាបន្ទាន់ ទៅរកថាមពលដែល អាចកើតឡើងវិញកាត់បន្ថយការបញ្ចេញកាបូនិក និងវិនិយោគលើដំណោះស្រាយប្រកបដោយនិរន្តរភាព។

## Goal 15: LIFE ON LAND

*Save our forests, protect our land, respect wildlife!*

## គោលដៅទី ១៥៖ ជីវិតនៅលើដី

ការថែរក្សាព្រៃឈើ ការពារដីរបស់យើង គោរពជីវិតសត្វព្រៃ!

Forests cover nearly 31 per cent of our planet’s land area. From the air we breathe, to the water we drink, to the food we eat – forests sustain us. Forests are home to more than 80% of all terrestrial species of animals, plants and insects. However, biodiversity is declining faster than at any other time in human history.

One fifth of the Earth’s land area (more than 2 billion hectares) are degraded, affecting 3.2 billion people, driving species to extinction and intensifying climate change. The Covid-19 pandemic has also highlighted the increase in zoonotic epidemics, which causes illness, death, the loss of livestock and livelihoods. As the world responds to and recovers from the current pandemic, it will need a robust plan for protecting nature, so that nature can protect humanity.

ព្រៃឈើគ្របដណ្តប់ជិត ៣១ ភាគរយនៃផ្ទៃផែនដីរបស់យើង។ ចេញពីខ្យល់ដែលយើងដកដង្ហើម ទឹកដែលយើងផឹក រហូតដល់អាហារដែលយើងបរិភោគ - ព្រៃឈើទ្រទ្រង់ជីវិតយើង។ ព្រៃឈើជាជម្រកនៃសភាវមានជីវិត ទាំងអស់ ដូចជាសត្វ ដើមឈើ និងសត្វល្អិត រហូត ៨០ ភាគរយ។ ទោះយ៉ាងណាក៏ដោយ រាល់ជីវចម្រុះកំពុងថយចុះ យ៉ាងលឿនជាងពេលណាៗទាំងអស់ក្នុងប្រវត្តិសាស្រ្តមនុស្សយើង។

មួយភាគប្រាំ នៃផ្ទៃផែនដី (ជាង ២ ពាន់លានហិកតា) ត្រូវបានបំផ្លាញ ដែលប៉ះពាល់ដល់មនុស្ស ៣,២ កោដនាក់ បង្កអោយសត្វមានជីវិតទៅរកការផុតពូជ និងការកើនឡើងនៃបម្រែបម្រួល អាកាសធាតុ។ ការរីករាលដាលនៃមេរោគ

Covid-19 ក៏បានបង្ហាញពីការកើនឡើង នៃ ជំងឺរាតត្បាត ដែលបង្កឱ្យមានជំងឺ ការស្លាប់ ការបាត់បង់សត្វពាហនៈ និងការចិញ្ចឹមជីវិត។ នៅពេលពិភពលោកងើបឡើងវិញពីជំងឺរាតត្បាតនាពេលបច្ចុប្បន្នវា នឹងត្រូវការផែនការយ៉ាងជាក់លាក់មួយសម្រាប់ការពារធម្មជាតិ ដូច្នេះទើបធម្មជាតិអាចការពារមនុស្ស ជាតិវិញបាន។

---

**Links:**
https://www.un.org/sustainabledevelopment/sustainable-development-goals

http://csdgs.org